ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា

# លក្ខន្តិកស្តីពីភារកិច្ចសម្រាប់អ្នកស្រាវជ្រាវវិទ្យាសាស្ត្រពេញម៉ោង

# នៃ

# វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា

យោង៖

- សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាប្រជាជនបដិវត្តន៍កម្ពុជា លេខ៣៦សរច ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ ១៩៨១ ស្តីពីការបង្កើតវិទ្យាស្ថានបច្ចេកទេសជាន់ខ្ពស់កម្ពុជា សូវៀត
- លក្ខន្តិករបស់ វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា។

សម្រេច

ប្រការ ១៖ អ្នកស្រាវជ្រាវវិទ្យាសាស្ត្រគឺជាសាស្ត្រាចារ្យ នៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា (វ.ប.ក) ឬអ្នកជំនាញខាងក្រៅ វិទ្យាស្ថាន ដែលត្រូវបានជ្រើសរើសតាមលក្ខណៈវិនិច្ឆ័យដូចខាងក្រោម៖

- មានចំណាប់ចំណូលចិត្ត និងគំនិតផ្តួចផ្តើមក្នុងការងារស្រាវជ្រាវវិទ្យាសាស្ត្រ
- ត្រូវមានសញ្ញាប័ត្រចាប់ពីថ្នាក់បរិញ្ញាប័ត្រជាន់ខ្ពស់ឡើង ប្រកបដោយសមត្ថភាពស្រាវជ្រាវ
- មានអាកប្បកិរិយា សីលធម៌រស់នៅ និងទំនាក់ទំនងល្អ។

ប្រការ ២៖ ការជ្រើសរើស អ្នកជ្រាវវិទ្យាសាស្ត្រពេញម៉ោង ជាបន្ទុករបស់ក្រុមប្រឹក្សាវិទ្យាសាស្ត្រ វ.ប.ក។ បេក្ខជនត្រូវ ដាក់ពាក្យស្នើសុំមកក្រុមប្រឹក្សាវិទ្យាសាស្ត្រ វ.ប.ក។

ប្រការ ៣៖ ក្រុមប្រឹក្សាវិទ្យាសាស្ត្រមានសមាសភាពដូចខាងក្រោម៖

- គណៈកម្មាធិការនាយកវិទ្យាស្ថាន
- ប្រធានដេប៉ាតឺម៉ង់ទាំងអស់
- អ្នកទទួលបន្ទុកកិច្ចការស្រាវជ្រាវវិទ្យាសាស្ត្រនៅតាមដេប៉ាតឺម៉ង់។

ប្រការ ៤៖ អ្នកស្រាវជ្រាវវិទ្យាសាស្ត្រពេញម៉ោង ត្រូវមានភារកិច្ចដូចខាងក្រោម៖

- ចំណាយពេលពេញម៉ោងសម្រាប់សកម្មភាពស្រាវជ្រាវនៅវ.ប.ក (គ្មានការបង្រៀន)
- ធានានិរន្តភាពនៃដំណើរការស្រាវជ្រាវវិទ្យាសាស្ត្រ
- ធ្វើរបាយការណ៍ប្រចាំឆមាសជូនក្រុមប្រឹក្សាវិទ្យាសាស្ត្រ វ.ប.ក

- ធ្វើទំនាក់ទំនងផ្ទាល់ជាមួយស្ថាប័ននានា ដើម្បីទាញយកគម្រោង ស្រាវជ្រាវ
- ចូលរួមក្នុងការដឹកនាំគម្រោងនិក្ខេបបទ សម្រាប់និស្សិតវិស្វករ បរិញ្ញាប័ត្រជាន់ខ្ពស់ និង ថ្នាក់បណ្ឌិត
- ចូលរួមក្នុងកិច្ចការសេវាសាធារណៈ និងសេវាសង្គម
- ចូលរួមក្នុងសន្និសីទស្រាវជ្រាវវិទ្យាសាស្ត្រជាតិ ឬអន្តរជាតិ យ៉ាងតិចម្តងក្នុងមួយឆ្នាំដើម្បីធ្វើបទបង្ហាញពីលទ្ធផលនៃការស្រាវជ្រាវរបស់ខ្លួន
- បោះពុម្ពជាទៀងទាត់នូវលទ្ធផលស្រាវជ្រាវក្នុងព្រឹត្តិប័ត្រវិទ្យាសាស្ត្រជាតិ ឬអន្តរជាតិ (យ៉ាងតិចមួយក្នុងមួយឆ្នាំ)
- ក្នុងករណី អ្នកស្រាវជ្រាវវិទ្យាសាស្ត្រ មិនអាចចូលរួមសន្និសីទស្រាវជ្រាវវិទ្យាសាស្ត្រជាតិ ឬ អន្តរជាតិ ឬមិនបោះពុម្ពលទ្ធផលស្រាវជ្រាវវិទ្យាសាស្ត្រ ក្រុមប្រឹក្សាវិទ្យាសាស្ត្រនឹងវាយតម្លៃក្នុង ការបន្ត លើការស្រាវជ្រាវវិទ្យាសាស្ត្រនៅ វ.ប.ក។

ប្រការ ៥៖ អ្នកស្រាវជ្រាវវិទ្យាសាស្ត្រពេញម៉ោង នឹងទទួលបាន៖

- ប្រាក់ឧបត្ថម
- ការលើកទឹកចិត្តក្នុងការទាញយកគម្រោងស្រាវជ្រាវ
- ការលើកទឹកចិត្តក្នុងការបោះពុម្ពផ្សាយកិច្ចការស្រាវជ្រាវ។

ប្រការ៦៖ អ្នកស្រាវជ្រាវវិទ្យាសាស្ត្រត្រូវចុះកិច្ចសន្យាជាមួយ វ.ប.ក ក្នុងអំឡុង១ឆ្នាំម្តង។

ប្រការ៧៖ វ.ប.ក មានសិទ្ធិកែប្រែលក្ខន្តិកនេះក្នុងករណីចាំបាច់។

ប្រការ៨៖ អ្នកស្រាវជ្រាវវិទ្យាសាស្ត្រពេញម៉ោងវ.ប.ក ត្រូវគោរពនូវលក្ខន្តិកនេះឱ្យមាន ប្រសិទ្ធភាពខ្ពស់។

ប្រការ៩៖លក្ខន្តិកនេះមានប្រសិទ្ធភាពអនុវត្តន៍ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ភ្នំពេញថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០១២

នាយកវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា

Institut de Technologie du Cambodge

បណ្ឌិត អុម រម្យរេ

<u>ចម្លងជូន:</u>

- ប្រធានក្រុមប្រឹក្សាភិបាលវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា
- គណៈគ្រប់គ្រងវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា
- ឯកសារ វ.ប.ក